# បទឧក្រិដ្ឋធ្វើមនុស្សគ្រប់គ្នាទទួលរងការឈឺចាប់ យើងអាចជួយបាន



CALIFORNIA CalVCB VICTIM COMPENSATION BOARD

## តើខ្ញុំអាចទទួលបានជំនួយដោយរបៀបណា?

ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងសំណងសម្រាប់ជនរងគ្រោះកាលីហ្វ័រញ៉ា (CalVCB) ប្តេជ្ញាធ្វើការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុសម្រាប់ការចំណាយដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋជាច្រើន។

ជនរងគ្រោះដែលរងរបួសផ្លូវកាយ ទទួលរងការគំរាមកំហែងលើការបង្ករបួសផ្លូវកាយ ឬការរងរបួសផ្លូវចិត្តដែលបណ្តាលមកពីបទឧក្រិដ្ឋដែលប្រើអំពើហិង្សាអាចមានសិទ្ធិទទួលបានជំនួយ។

ដើម្បីទទួលបានជំនួយ បុគ្គលនោះត្រូវតែជាជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌដែលមានសិទ្ធិ។ សម្រាប់បទឧក្រិដ្ឋជាក់លាក់មួយចំនួន ការរងរបួសផ្លូវចិត្តគឺមានសិទ្ធិគ្រប់គ្រាន់ដើម្បីទទួលបានជំនួយនេះហើយ។ សមាជិកគ្រួសារ និងមនុស្សជាទីស្រលាញ់ក៏អាចមានសិទ្ធិទទួលបានផងដែរ។

## តើខ្ញុំត្រូវដាក់ពាក្យស្នើសុំយ៉ាងដូចម្តេច?

- ទាញយកពាក្យស្នើសុំតាមរយៈ: **victims.ca.gov** ហើយផ្ញើពាក្យនេះទៅកាន់អាសយដ្ឋានខាងក្រោម
- ទូរស័ពុទទៅលេខ **1-800-777-9229**
- សម្រាប់ជំនួយក្នុងតំបន់ សូមចូលទៅកាន់ **victims.ca.gov/victims/localhelp.aspx** ដើម្បីស្វែងរកអ្នកគាំទ្រសម្រាប់ជនរងគ្រោះនៅតំបន់ជិតៗ ដែលអាចជួយអ្នកធ្វើការដាក់ពាក្យស្នើសុំ និងត្រួសត្រាយផ្លូវពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

## តើព័ត៌មានអ្វីផ្សេងទៀតដែលអាចមានប្រយោជន៍?

- បង្កាន់ដៃនៃការចំណាយពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ
- វិក្កយបត្រថ្លៃព្យាបាលជំងឺ សុខភាពមាត់ធ្មេញ ឬសុខភាពផ្លូវចិត្តពាក់ព័ន្ធនឹងបទព្រហ្មទណ្ឌនោះ
- បណ្ណធានារ៉ាប់រងសុខភាព

### វិធីដែល CALVCB បានជួយដល់ជងរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌយ៉ាងដូចម្តេចខ្លះនៅក្នុងឆ្នាំ 2017




### គ្របដណ្តប់លើបទល្មើសព្រហ្មទណ្ឌដូចជា៖

- ការវាយប្រហារមកលើរាងកាយ
- រំលោភបំពានលើកុមារ
- អំពើហិង្សាក្នុងគ្រួសារ
- បើកបរពេលស្រវឹង
- រំលោភបំពានលើមនុស្សចាស់
- បទព្រហ្មទណ្ឌពាន់ព័ន្ធនឹងការស្អប់ខ្ពើម
- ឃាតកម្ម
- ការជួញដូរមនុស្ស
- ការឃាឃីលើបណ្តាញអ៊ីនធឺណិត
- ចោរកម្ម
- ការបំពានផ្លូវភេទ
- ការលបតាមដាន
- ការលបតាមដាន
- មនុស្សឃាតដោយអចេតនាដោយសារយានជំនិះ

### CalVCB អាចជួយទូទាត់សម្រាប់៖

- ការផ្តល់ប្រឹក្សា
- ការព្យាបាលជំងឺ និងមាត់ធ្មេញ
- ការបាត់បង់ប្រាក់ចំណូល
- ការចំណាយលើបុណ្យសព និងបញ្ចុះសព
- សុវត្ថិភាពលំនៅដ្ឋាន
- បរិក្ខារពេទ្យ ប្រសិនបើបាត់ ឬត្រូវគេលួច
- ផ្ទះ ឬការកែសម្រួលយាន្តជំនិះ ធ្វើដំណើរតាមស្ថានភាពរបស់ជនរងគ្រោះដែលក្លាយជាជនពិការ
- ការសម្អាតកន្លែងកើតហេតុ
- ការប្តូរទីលំនៅ

លទ្ធភាពក្នុងការផ្តល់ជូនចំពោះការបាត់បង់នីមួយៗមានកម្រិត។

Khmer | rev. 6.22.2018